ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

-សាលក្រមព្រហ្មទណ្ឌលេខ ៥០៧ "ជ១" ក្រ១១ ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២៣
-សំណុំរឿងព្រហ្មទណ្ឌលេខ ៥៦០៧ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២២
-សំណុំរឿងស៊ើបសួរលេខ ៤២០៥ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២២
-សំណុំរឿងជំនុំជម្រះលេខ ១៥៨៨ ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២៣

នាងនាមប្រជារាស្ត្រខ្មែរ
សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២៣ វេលាម៉ោង ០៩ : ០០ នាទី នៅសាលសវនាការទី១ ជាន់ផ្ទាល់ដី ដោយមានសមាសភាព៖

ក្រុមប្រឹក្សាជំនុំជម្រះ

លោកអនុប្រធាន [redacted] ប្រធានក្រុមប្រឹក្សាជំនុំជម្រះ
លោក ចៅក្រមប្រឹក្សា
លោកស្រី ចៅក្រមប្រឹក្សា

តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

ក្រឡាបញ្ជីសវនាការ

លោកស្រី [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ៥៦០៧ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២២ រវាងជនជាប់ចោទ៖

ឈ្មោះ [redacted] **បញ្ញាពេជ្រ ហៅ យ៉ាកី** ភេទប្រុស អាយុ១៦ឆ្នាំ (០៩-វិច្ឆិកា-២០០៦) ជនជាតិខ្មែរ ទីកន្លែងកំណើត [redacted] ក្រុងភ្នំពេញ ទីលំនៅមុនពេលឃាត់ខ្លួនស្នាក់នៅផ្ទះលំភូមិឃ្លាំងសាំង សង្កាត់ឬស្សីកែវ ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] សាមិត្ត (ស្លាប់) ម្តាយឈ្មោះ [redacted] ចន្ថី (រស់) នៅលីវ ជារអនីតិជន ។ ដោយមានលោក [redacted] សុភក្តិ ជាមេធាវីការពារសិទ្ធិ ។

-ឃុំខ្លួននៅ (PJ) តាមដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ៩៣៧២ "ឧ" ដ.ឃ.ដ ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ ២០២២ ។

<u>ជាប់ចោទពីបទ</u>៖ **ល្មួចមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅចំណុចផ្លូវលេខ១០០ កែងផ្លូវព្រះស៊ីសុវត្ថិ ភូមិ ០៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២២ តាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

ជនរងគ្រោះឈ្មោះ [redacted] **វង្ស** ភេទប្រុស អាយុ៥០ឆ្នាំ មានអាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ២៣ ផ្លូវលេខ ៣១១ ភូមិគោកឃ្លាំង សង្កាត់គោកឃ្លាំង ខណ្ឌសែនសុខ រាជធានីភ្នំពេញ ។

អត្ថហេតុនៃរឿងអាងដូចតទៅ

កាលពីថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២២ វេលាម៉ោង ១៥ និង ៥០ នាទី ជនរងគ្រោះឈ្មោះ [redacted] វង្ស ចុះពីលើរថយន្តមានយួរកាបូបដៃ បំណងដើរចូលការហ្វេ នៅចំណុចផ្លូវលេខ១០០ កែងផ្លូវព្រះស៊ីសុវត្ថិ ភូមិ០៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ស្រាប់តែឈ្មោះ ចំរើន ឈ្មោះ រ៉ុង និងឈ្មោះ [redacted] បញ្ញាពេជ្រ ជិះម៉ូតូមកធ្វើសកម្មភាពឆក់កាបូបរបស់ជនរងគ្រោះបានសម្រេច ភ្លាមនោះជនរងគ្រោះស្រែកឆោរឆ្ងោ សមត្ថកិច្ចដែលកំពុងយាមល្បាតបានចាប់ឃាត់ខ្លួនបានឈ្មោះ ទេព បញ្ញាពេជ្រ រួមទាំងវត្ថុតាងតែម្តង ។

-**បានឃើញ** ដីកាសន្និដ្ឋានស្តាពរលេខ ១០២៧ អ.ឃ.ន ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២៣ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-**បានឃើញ** ដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះលេខ ១៤៩៨ (ក១) ដ.ដ ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] **បញ្ញាពេជ្រ ហៅ ឆ័កឹ** បានឆ្លើយថា៖ កាលពីថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២២ ម៉ោងប្រហែល ១៤ និង ៣០ នាទី ខ្លួនជិះម៉ូតូម៉ាកស្កុបពី ពណ៌ក្រហម ពាក់ស្លាកលេខ ភ្នំពេញ 1JE-3570 ម្នាក់ឯង មកដល់វត្តភ្នំ ក៏ជួបឈ្មោះ ចំរើន ជិះម៉ូតូ NEX ឌុបឈ្មោះ រ៉ុង មកបបួលខ្លួនធ្វើសកម្មភាពឆក់ទ្រព្យសម្បត្តិប្រជាពលរដ្ឋ ខ្លួនក៏ព្រម ។ លុះមកដល់ចំណុចកើតហេតុ ក៏បានឃើញបុរសម្នាក់កំពុងដើរកាន់កាបូបពណ៌ខ្មៅ ឈ្មោះ ចំរើន បានជិះម៉ូតូអែបក្បែរនោះ រួចឈ្មោះ រ៉ុង ឆក់កាបូបនោះបានសម្រេច ពួកខ្លួនក៏បានជិះគេច រហូតដល់រង្វង់មូលក្លួចកាណុង ក៏ត្រូវបានសមត្ថកិច្ចឃាត់ខ្លួនរូបខ្លួនបាន ។

-ដើមបណ្តឹងឈ្មោះ [redacted] **វង្ស** បានឆ្លើយថា៖ កាលពីថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២២ ម៉ោងប្រហែល ១៥ និង ២០ នាទី ខ្លួនជិះរថយន្តម៉ាករ៉ៃហ្វ ពណ៌ទឹកប្រាក់ ចេញពីមុខវាំង មកចតនៅមុខប្រៃសណីយ៍ រួចខ្លួនបានយកទូរស័ព្ទដៃម៉ាក Iphone 6 និងវិទ្យុទាក់ទង ID ដាក់ចូលក្នុងកាបូបយួរដៃ ពណ៌ខ្មៅ ចុះពីលើឡាន គោលបំណងដើរចូលហាងការហ្វេ ស្រាប់តែមានជនជាប់ចោទ០៣នាក់ ឈ្មោះ ចំរើន ឌុបឈ្មោះ រ៉ុង ជិះម៉ូតូអែបក្បែរខ្លួន ឈ្មោះ រ៉ុង យកដៃខាងឆ្វេងឆក់កាបូបយួរដៃរបស់ខ្លួនបានសម្រេច រួចប្រគល់ឲ្យឈ្មោះ [redacted] បញ្ញាពេជ្រ ដែលជិះម៉ូតូតាមពីក្រោយ ខ្លួនស្រែកឆោរឆ្ងោ ស្របពេលកម្លាំងសមត្ថកិច្ចកំពុងល្បាតក្បែរនោះ ក៏ជួយអន្តរាគមន៍ចាប់បានឈ្មោះ [redacted] បញ្ញាពេជ្រ តែម្តង ។

សេចក្តីសន្និដ្ឋានលើកសំុរបស់តំណាងអយ្យការ

ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ និងចម្លើយរបស់ដើមបណ្តឹង ឃើញថា ស៊ីសង្វាក់ទៅនឹងអង្គហេតុដែលបានធ្វើការចោទប្រកាន់ ដូចនេះ សុំតម្កល់ការចោទប្រកាន់តាមដីកាសន្និដ្ឋានស្តាពរលេខ ១០២៧ អ.ឃ.ន ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២៣ ទុកនៅដដែល និងប្តឹងសុំឱ្យផ្តន្ទាទោសតាមច្បាប់ ។

សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

ក្រោយពីបានស្តាប់ការសាកសួរនាពេលសវនាការ ឃើញថា កូនក្តីរបស់ខ្លួនបានទទួលស្គាល់កំហុស ហើយជនរងគ្រោះក៏ពុំមានរងរបួសស្នាមដែរ ហេតុនេះអង្គហេតុគឺជាបទល្មើសលួចនោះទេ ដូច្នេះខ្លួនស្នើសុំក្រុមប្រឹក្សាពិចារណា កែប្រែការចោទប្រកាន់ ម៉្យាងជនជាប់ចោទជាអនីតិជន ហើយអះអាងថាកែខ្លួន ដូចនេះស្នើសុំឱ្យក្រុមប្រឹក្សាបន្ធូរបន្ថយទោសតាមមាត្រា ៩២ និងមាត្រា ៩៣ និងកែប្រែបទចោទប្រកាន់ ពីមាត្រា ៣៥៧ និងមាត្រា ៣៥៣ នៃក្រមព្រហ្មទណ្ឌ ។

សម្តីចុងក្រោយរបស់ជនជាប់ចោទ

-ជនជាប់ចោទឈ្មោះ [redacted] បញ្ញាពេជ្រ ហៅ យ៉ាកឺ បានស្នើសុំឲ្យតុលាការបន្ធូរបន្ថយទោស ។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់ចម្លើយរបស់ដើមបណ្តឹង

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

-ក្រោយពីបានស្តាប់សម្តីចុងក្រោយរបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យឯកសារភស្តុតាងនានា

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

សំអាងហេតុ

១-តាមដីកាសម្រេចបញ្ជូនរឿងទៅជម្រះលេខ ១៤៩៨ (ក១) ដ.ដ ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរ បានសម្រេចបញ្ជូនឈ្មោះ [redacted] **បញ្ញាពេជ្រ ហៅ យ៉ាកឺ** ទៅជំនុំជម្រះ ពីបទ៖ **ល្មួចមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅចំណុចផ្លូវលេខ១០០ កែងផ្លូវព្រះស៊ីសុវត្ថិ ភូមិ០៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២២ តាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

២-តាមចម្លើយសារភាពរបស់ជនជាប់ចោទ ដែលបានឆ្លើយថា៖ ឈ្មោះ ចំរើន និងឈ្មោះ រ៉ុង បបួលខ្លួនឆក់ទ្រព្យសម្បត្តិរបស់ប្រជាពលរដ្ឋ ដោយឈ្មោះ ចំរើន ជាអ្នកឌុប ឈ្មោះ រ៉ុង ជាអ្នកឆក់កាបូបយួរដៃពីជនរងគ្រោះ រួចហុចមកឲ្យខ្លួន ដែលជិះម៉ូតូតាមពីក្រោយ តែត្រូវបានសមត្ថកិច្ចដែលកំពុងល្បាត ដេញចាប់រូបខ្លួនបានតែម្តង ឯពីរនាក់នោះជិះម៉ូតូគេចខ្លួនបាត់ហើយ ។

-តាមចម្លើយរបស់ដើមបណ្តឹង ដែលបានឆ្លើយថា៖ ពេលខ្លួនចុះពីឡាន គោលបំណងដើរចូលហាងកាហ្វេ ដោយមានកាន់កាបូបយួរដៃ ស្រាប់តែឈ្មោះ ចំរើន ឌុបឈ្មោះ រ៉ុង ជិះម៉ូតូរែបក្បែរខ្លួន ហើយឈ្មោះ រ៉ុង ប្រើដៃខាងឆ្វេងឆក់កាបូបយួរដៃពីខ្លួនបានសម្រេច រួចប្រគល់ឲ្យឈ្មោះ ទេព បញ្ញាពេជ្រ ដែលជិះតាមពីក្រោយ ប៉ុន្តែត្រូវសមត្ថកិច្ចដែលកំពុងល្បាត ដេញចាប់បានឈ្មោះ [redacted]បញ្ញាពេជ្រ ។

៣-តាមចម្លើយរបស់ជនជាប់ចោទ នៅគ្រប់ដំណាក់កាល និងចម្លើយរបស់ជនរងគ្រោះ ព្រមទាំងភស្តុតាងមានភាពស៊ីចង្វាក់គ្នាដែលអាចបញ្ជាក់បានថា កាលពីថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២២ វេលាម៉ោង ១៥និង៥០នាទី នៅចំណុចផ្លូវលេខ១០០ កែងផ្លូវព្រះស៊ីសុវត្ថិ ភូមិ០៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ មានករណី **ល្មួចមានស្ថានទម្ងន់ទោស** ដែលបង្កឡើងដោយជនជាប់ចោទឈ្មោះ [redacted] **បញ្ញាពេជ្រ ហៅ យ៉ាកឺ** ។

៤-មាត្រា ៣៥៣ នៃក្រមព្រហ្មទណ្ឌ បានបញ្ញត្តិថា "***អំពើល្មួច*** *គឺជាអំពើដកហូតដោយទុច្ចរិតនូវទ្រព្យសម្បត្តិ ឬវត្ថុផ្សេងទៀតរបស់អ្នកដទៃ តាមគ្រប់មធ្យោបាយក្នុងគោលបំណងយកមកធ្វើជាកម្មសិទ្ធិរបស់ខ្លួន* " ដូច្នេះឃើញថាសកម្មភាពដែលជនជាប់ចោទបានប្រព្រឹត្តគឺល្មើសទៅនឹងមាត្រា ៣៥៣ នៃក្រមព្រហ្មទណ្ឌ ។

-អំពើប្រព្រឹត្តរបស់ជនជាប់ចោទ គឺបានធ្វើសកម្មភាពជាក្រុម ដោយមានអ្នកឌុប និងមានអ្នកឆក់កាបូបពីជនរងគ្រោះ ហើយប្រគល់ឲ្យទៅម៉ូតូដែលជិះពីក្រោយទៀតផង ដែលនេះជាអំពើល្មើសច្បាប់ដែលបានចែងឱ្យផ្តន្ទាទោស ពីបទ **ល្មួចមានស្ថានទម្ងន់ទោស** តាមបញ្ញត្តិមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

៥-តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ បានប្តឹងសុំរក្សាបទចោទនៅដដែល ព្រោះមានចម្លើយនិងភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់ ការប្តឹងសុំនោះមានលក្ខណៈត្រឹមត្រូវតាមច្បាប់កំណត់ ។

៦-ការប្រព្រឹត្តអំពើល្មើសរបស់ជនជាប់ចោទធ្វើឡើងដោយមានចេតនា និងមានស្មារតីទទួលខុសត្រូវគ្រប់គ្រាន់ និងជាអំពើដែលធ្វើឱ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពរបស់ជនរងគ្រោះ ហើយបំពានលើនីតិរដ្ឋ ភាពសង្គម ដែលច្បាប់បានការពារយ៉ាងម៉ឺងម៉ាត់បំផុត ។

៧-មានភស្តុតាងដាក់បន្ទុក និងពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted] **បញ្ញាពេជ្រ ហៅ យ៉ាកឹ** ពីបទ៖ **ល្មើចមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅចំណុចផ្លូវលេខ១០០ កែងផ្លូវព្រះស៊ីសុវត្ថិ ភូមិ០៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២២ តាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

៨-ដើមបណ្តឹងពុំប្តឹងទាមទារសំណងជម្ងឺចិត្តទេ ហេតុនេះតុលាការមិនអាចពិចារណា និងសម្រេចបានទេ ។

ហេតុផ្លែងសម្រេច

ផ្តន្ទាទោសឈ្មោះ [redacted] **បញ្ញាពេជ្រ ហៅ យ៉ាកឹ** អាទប្រុស អាយុ១៦ឆ្នាំ ជនជាតិខ្មែរ (ដែលមានសាវតាជាតិដូចខាងលើ) **ដាក់ពន្ធនាគារកំណត់ ០១ ឆ្នាំ និង ០៦ ខែ (មួយឆ្នាំ និងប្រាំមួយខែ) ពីបទ: ល្មើចមានស្ថានទម្ងន់ទោស** ប្រព្រឹត្តនៅចំណុចផ្លូវលេខ១០០ កែងផ្លូវព្រះស៊ីសុវត្ថិ ភូមិ០៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២២ តាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ ។

សាលក្រមនេះ ជំនុំជម្រះ នៅថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០២៣ និងប្រកាសជាសាធារណៈ នៅថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២៣ ចំពោះមុខជនជាប់ចោទ និងដើមបណ្តឹង ។

រក្សាសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ៕

ក្រឡាបញ្ជីសវនាការ	ចៅក្រមប្រឹក្សា	ចៅក្រមប្រឹក្សា	ប្រធានក្រុមប្រឹក្សា
ហត្ថលេខា និងត្រា	ហត្ថលេខា	ហត្ថលេខា	ហត្ថលេខា និងត្រា
[redacted]			

.....

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃអង្គារ ៨កើត ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ, ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២៣

ក្រឡាបញ្ជី

[redacted]

បានឃើញ

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]